ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.........................................................

# សុន្ទរកថា
## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១៥
## នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៦
## ថ្ងៃសុក្រ ៣រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
## រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦

សូមគោរពៈ

- គណៈអធិបតី
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានមកចូលរួមក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១១៥ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២៦ សម្រាប់មន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា។ ការប្រារព្ធពិធីខួបអនុស្សាវរីយ៍នេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ដើម្បីផ្តល់ឱកាសឱ្យមន្ត្រីបុគ្គលិកយើងទាំងអស់បានជួបជុំសំណេះសំណាលគ្នាក៏ដូចជាចូលរួមអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ព្រមទាំងលើកកម្ពស់ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកជានារីនៅធនាគារជាតិនៃកម្ពុជា ដែលបាន និងកំពុងរួមចំណែកយ៉ាងសំខាន់ក្នុងការកសាង អភិវឌ្ឍ និងលើកកម្ពស់វិស័យធនាគារ និងសង្គមជាតិកម្ពុជាឱ្យមានការរីកចម្រើនជាបន្តបន្ទាប់។

ឆ្នាំនេះ យើងប្រារព្ធទិវានេះក្រោមប្រធានបទ "**សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ**" ក្នុងគោលបំណងរំលេចពីសារៈសំខាន់មិនអាចកាត់ថ្លៃបាននៃសន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី និងក្រុមគ្រួសារ ដែលជាបុរេលក្ខខណ្ឌដ៏ចម្បងនាំឱ្យស្ត្រី និងក្រុមគ្រួសារទទួលបានការរស់នៅជួបជុំប្រកបដោយសុភមង្គល សុខដុមរមនា សុខុមាលភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ដែលជាកត្តាជំរុញដល់ការរួមចំណែកយ៉ាងសកម្មរបស់ស្ត្រីក្នុង



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការកសាង ថែរក្សា និងការពារសន្តិភាព ដែលជាធាតុផ្សំមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព ស្ថិរភាព និងវិបុលភាព។

ប្រធានបទនេះ ក៏បានឆ្លើយតបទៅនឹងក្របខ័ណ្ឌសកលនៃរបៀបវារៈស្តីពី **"ស្ត្រី សន្តិភាព និងសន្តិសុខ"** របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដែលបានឆ្លុះបញ្ចាំងពីការលើកកម្ពស់ស្ត្រី និងក្មេងស្រីក្នុងការចូលរួមកសាង ថែរក្សាសន្តិភាព និងសន្តិសុខយូរអង្វែង។

ជាមួយគ្នានេះ ខ្ញុំសូមលើកទឹកចិត្តឱ្យស្ត្រី និងបុរសមានសិទ្ធិនិងឱកាសស្មើគ្នាក្នុងការទទួលបាននូវការអប់រំ ចំណេះដឹង ជំនាញវិជ្ជាជីវៈ និងការចូលរួមគ្រប់វិស័យ។ ជាក់ស្តែង ស្ត្រីមិនត្រឹមតែជាកម្លាំងសំខាន់ក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែក៏ជាដៃគូដ៏មានតម្លៃក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងស្ថាប័នផងដែរ ដោយសារស្ត្រីមានភាពអត់ធ្មត់ ប្រាជ្ញាស្មារតីទទួលខុសត្រូវខ្ពស់ ដែលជាគុណតម្លៃដ៏សំខាន់ក្នុងការថែរក្សាសុខសន្តិភាពក្នុងគ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ស្របតាមទិសដៅនេះ ធនាគារជាតិនៃកម្ពុជា តែងតែយកចិត្តទុកដាក់លើការលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រ ទាំងក្នុងក្របខ័ណ្ឌស្ថាប័ន និងក្នុងការគាំទ្រការអភិវឌ្ឍសង្គមជាតិ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជា ជានិច្ចកាលតែងតែសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការគាំទ្រ និងបង្កើតកម្មវិធីនានាសម្រាប់លើកកម្ពស់ស្ត្រី និងការពង្រឹងឱកាសឱ្យស្ត្រីអាចទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព ព្រមទាំងរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ការងារនេះ មិនត្រឹមតែជួយពង្រឹងសេដ្ឋកិច្ចគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយលើកកម្ពស់ស្ថិរភាព និងភាពធន់របស់សង្គមផងដែរ។ ទន្ទឹមនេះយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានដាក់ចេញ ដោយផ្តោតលើការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ ការបញ្ចូលអក្ខរកម្មហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅ និងការលើកទឹកចិត្តឱ្យប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថលជាដើម។ ជាមួយគ្នានេះ គិតត្រឹមខែមករា ឆ្នាំ២០២៦ ចំនួនអ្នកខ្ចីពីគ្រឹះស្ថានធនាគារមានប្រមាណ ៥៣.៧% ជាស្ត្រី និងចំនួនអ្នកខ្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានប្រមាណ ៥៨.៦% ជាស្ត្រី ខណៈចំនួនអ្នកដាក់ប្រាក់បញ្ញើក្នុងគ្រឹះស្ថានធនាគារមានប្រមាណ ៥១.២% ជាស្ត្រី និងចំនួនអ្នកដាក់ប្រាក់បញ្ញើក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៦៣.៩% ជាស្ត្រី។ ទាំងនេះបង្ហាញពីសមាមាត្រដែលស្ត្រីបានចូលរួមទទួល និងប្រើប្រាស់សេវាហិរញ្ញវត្ថុប្រហាក់ប្រហែលនឹងបុរស។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំបង្កើតទារកដ្ឋាននៅអគារសែនសុខ និងអគារស្នាក់ការកណ្តាលដែលយើងកំពុងសាងសង់ក្នុងគោលបំណងលើកទឹកចិត្ត ជួយសម្រាលបន្ទុក និងលើកកម្ពស់តុល្យភាពរវាងជីវិតការងារ និងជីវិតគ្រួសារដល់មន្ត្រីជាស្ត្រី ព្រមទាំងអាចឱ្យស្ត្រីមានលទ្ធភាពធ្វើការងារប្រកបដោយប្រសិទ្ធភាព និងមានពេលវេលាថែទាំទារកប្រកបដោយសុវត្ថិភាព គុណភាព និងស្តង់ដារ។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានស្នើសុំឱ្យមន្ត្រីជំនាញធ្វើការសិក្សាអំពីលទ្ធភាពក្នុងការតម្រូវឱ្យគ្រឹះស្ថានក្រោមឱវាទ មានសមាជិកក្រុមប្រឹក្សាភិបាលជាស្ត្រីយ៉ាងតិចម្នាក់ ក្នុងគោលដៅចម្បងចូលរួមចំណែកលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យហិរញ្ញវត្ថុ ដោយបង្កើនតួនាទីស្ត្រីក្នុងការសម្រេចចិត្ត និងភាពជាអ្នកដឹកនាំ។ ការចូលរួមរបស់ស្ត្រីក្នុងការដឹកនាំគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាកត្តាមួយក្នុងការរួមចំណែកបង្កើនប្រសិទ្ធភាព វឌ្ឍនភាព និងនវានុវត្តភាពក្នុងវិស័យហិរញ្ញវត្ថុផងដែរ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នៅក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដល់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបាននិងកំពុងបន្តបំពេញកិច្ចការក្នុងការការពារសន្តិភាព អធិបតេយ្យភាព និងបូរណភាពទឹកដី សម្រាប់បម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន ដែលជាធាតុផ្សំមិនអាចខ្វះបានក្នុងការបន្តគោលនយោបាយ និងយុទ្ធសាស្ត្រ ផ្តោតយ៉ាងជាក់លាក់ទៅលើការលើកកម្ពស់ សមភាពយេនឌ័រ ការបង្កើនភាពអង់អាចរបស់ស្ត្រី និងក្មេងស្រី សំដៅធានាបាននូវគុណតម្លៃរបស់ស្ត្រីក្នុងសង្គម ប្រកបដោយសីលធម៌ សមធម៌ បរិយាបន្ន និងការអភិវឌ្ឍជាតិ។ ទន្ទឹមនេះ ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមាន **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាព្រះប្រធានកិត្តិយស ជាចំណែកដ៏ថ្លៃថ្លាក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី តម្លៃស្ត្រី រួមទាំងសីលធម៌សង្គមប្រពៃណី និងវប្បធម៌ដ៏ល្អផូរផង់របស់កម្ពុជា។ ជាមួយគ្នានេះ ខ្ញុំក៏សូមថ្លែងការកោតសរសើរដល់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អគ្គស្នងការនៃសមាគមកាយឫទ្ធិនារីកម្ពុជា ប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ និងជាប្រធានកិត្តិយសមូលនិធិគន្ធបុប្ផា ដែលបានដឹកនាំកម្មវិធីមនុស្សធម៌ដល់ស្ត្រី និងក្រុមគ្រួសារ ដែលជាយោធិន យោធិនពលី និងជនភៀសសឹកក្នុងបរិការណ៍នៃវិបត្តិជម្លោះព្រំដែនកម្ពុជា-ថៃ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងកោតសរសើរ ចំពោះថ្នាក់ដឹកនាំនារី និងមន្ត្រីបុគ្គលិកនារីធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងខិតខំប្រឹងប្រែងក្នុងការជំរុញការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងយុគសម័យបរិវត្តកម្មឌីជីថល។ ការណ៍នេះ ក៏បានបង្ហាញថាស្ត្រីត្រូវបានចាត់ទុកជាដៃគូដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងគ្រួសារ តាមរយៈការជួយជំរុញការកសាង និងការអភិវឌ្ឍសមត្ថភាពស្ត្រី ក៏ដូចជាការផ្តល់ឱកាសឱ្យស្ត្រីចូលរួមប្រកបដោយសមធម៌ក្នុងគ្រប់ការងារនិងក្នុងគ្រប់វិស័យ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកនារីធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស សូមបានប្រកបតែនឹងសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងកម្មវិធីថ្ងៃនេះ និងសូមជូនពរឱ្យជួបប្រទះ តែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**